# សម្ភាសជាមួយឈ្មោះ នន ភន ភេទស្រី អាយុ៥០ ឆ្នាំ

## មុខងារខ្មែរក្រហមៈ កងដឹកជញ្ជូន

## មុខងារបច្ចុប្បន្នៈ ធ្វើចំការ

## មានស្រុកកំណើតនៅៈ ភូមិចេកចា ឃុំស្វាយចចីប ស្រុកបរសែត ខេត្តកំពង់ស្ពឺ

## សព្វថ្ងៃរស់នៅភូមិស្ទឹងថ្មី ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

## ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:៥១:៣៤

**ទំព័រ២៣**

ប៊ុនថន : អញ្ជើញដំបូងខ្ញុំសុំអនុញ្ញាតសម្ភាសន៍អ្នកមីង អ្នកមីងឲ្យខ្ញុំសម្ភាសន៍ទេអ្នកមីង?

ភន : ឲ្យ ។

ប៊ុនថន : ដំបូងនេះខ្ញុំសុំសួរឈ្មោះអ្នកមីង មីងឈ្មោះអីដែរ?

ភន : នោន ភន ។

ប៊ុនថន : មីងអាយុប៉ុន្មានឆ្នាំហើយ?

ភន : អាយុឥឡូវ៥០ ។

ប៊ុនថន : អ្នកមីងមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ភន : ស្រុកកំណើតនៅខេត្តកំពង់ស្ពឺ ស្រុកបាសែត ។

ប៊ុនថន : បាទ!ភូមិអីដែរ?

ភន : ភូមិចេកចា ឃុំស្វាយចចីប ។

ប៊ុនថន : អ្នកមីងមានបងប្អូនប៉ុន្មាននាក់?

ភន : ខ្ញុំមានបងប្អូន៧នាក់ តែបាត់២ នៅសល់៥ បាត់កាលសម័យយើង៣ឆ្នាំហ្នឹង អត់រកឃើញរហូតដល់ឥឡូវ ។

ប៊ុនថន : គាត់ចូលកងឬម៉េច?

ភន : ចា៎!ចូលកងៗហើយគាត់បាត់រហូតដល់ឥឡូវ ។

ប៊ុនថន : ស្រីឬប្រុស?

ភន : ស្រី១ ប្រុស១ ។

ប៊ុនថន ៖ មីងកូនទីប៉ុន្មាន?

ភន ៖ ខ្ញុំកូនទី៤ ។

ប៊ុនថន ៖ ចុះឪពុកម្ដាយមីងនៅរស់ទេ?

ភន ៖ ស្លាប់អស់ហើយ ។

ប៊ុនថន ៖ ស្លាប់នៅជំនាន់ណា?

ភន ៖ អត់ទេ ទើមស្លាប់ឥឡូវនេះដែរ ទើមស្លាប់ខែមុននេះដែរទេម៉ែខ្ញុំ បើឪខ្ញុំស្លាប់ឆ្នាំទៅ មិញ ។

ប៊ុនថន ៖ មីងបានរៀនសូត្រដល់ណាដែលកាលពីក្មេង?

ភន ៖ កាលពីក្មេងខ្ញុំរៀនដល់ថ្នាក់ទី១២ហ្នឹង អាថ្នាក់ទី១យើងឥឡូវហ្នឹង ហើយដល់ហើយគេមិនវ៉ាកង់ គេវ៉ាកង់ទៅគេថាវ៉ាកង់ធំៗរហូតកើតសង្គ្រាមបណ្ដោយ ។

ប៊ុនថន ៖ ឆ្នាំប៉ុន្មានកាលហ្នឹងមីង?

ភន ៖ ឆ្នាំមិនដឹងឆ្នាំប៉ុន្មាន កាលដែលខ្ញុំរៀនហ្នឹងមិនដឹងឆ្នាំប៉ុន្មានខ្ញុំមិនសូវដឹងដែរ ដល់តែម៉ោកើតសង្គ្រាមម៉ោខ្ញុំដឹងៗថា៧៣ អា៎ក!ជំនាន់យើងកើតសង្គ្រាមលន់ ណុលហ្នឹងក្រែង ។

ប៊ុនថន ៖ ឆ្នាំ៧០មីង?

ភន ៖ ហ្នឹងហើយឆ្នាំ៧៣ៗហ្នឹងខ្ញុំដឹង៧៣ ។

ប៊ុនថន ៖ មីងឈប់រៀនឆ្នាំ៧៣អញ្ចឹង?

ភន ៖ ចា៎!ខ្ញុំកាលវ៉ាកង់ហ្នឹងហើយឈប់រហូត ដល់ពេលក្រោយហ្នឹងក៏ ដល់ពេលខ្ញុំវ៉ាកង់ទៅគេឲ្យខ្ញុំដើរតាមកងទៅ គេឲ្យខ្ញុំរៀនៗតាមកង យើងនៅតាមខ្ទមស្រែតាមអីអញ្ចឹងដល់អញ្ចឹងគេឲ្យរៀនៗទៅក៏យន្ដហោះម៉ោអញ្ចឹងទៅផ្អើលឈប់រៀនទៀត ដល់ហើយហ៊ឹងក៏ចាប់ផ្ដើមរៀនទៀត រៀនអញ្ចឹងទៅអាបេយន្ដហោះទម្លាក់ហ្នឹងខានរៀនៗ ខ្ញុំខានរៀនរហូត ដល់អញ្ចឹងខ្ញុំក៏ចូលតាមកង យើងចូលកងកុមារ ដល់ចូលកងកុមារទៅខ្ញុំលើកទំនប់ រែកដីដំបូកដាក់ស្រែនោះៗលើកទំនប់ ដល់ក្រោយម៉ោខ្ញុំម៉ោនៅកងចល័តៗយើងតាកែវហ្នឹង ។

ប៊ុនថន ៖ អ្ហូ!ម៉ោនៅតាកែវ?

ភន ៖ ចា៎!ម៉ោនៅតាកែវហ្នឹងនៅកងចល័តបាន៣-៤ឆ្នាំនោះ ។

ប៊ុនថន ៖ តាកែវហ្នឹងនៅស្រុកណាវិញ?

ភន ៖ ស្រុក៥៥ ស្រុកព្រៃកប្បាស ។

ប៊ុនថន ៖ ហើយចូលកងហ្នឹងគេប្រមូលចូល ឬក៏?

ភន : យើងស្មគ្រចិត្តចូលខ្លួនយើងៗស្មគ្រចិត្តទៅកងចល័តហ្នឹង ដល់ទៅកងចល័តហ្នឹងឡើង ម៉ោលើដល់ហើយគេនាំឲ្យម៉ោបាត់ដំបង គេបញ្ជូនឲ្យម៉ោបាត់ដំបង ។

ប៊ុនថន : ខាងណាបញ្ជូនអ្នកមីង?

ភន : អង្គការយើងហ្នឹង បញ្ជូនមៅបាត់ដំបងថាម៉ោនៅបាត់ដំបង ។

ប៊ុនថន : ប្រធានកងប្អូមួយអ្នក?

ភន : ប្រធានកង ប្រធានគរ ប្រធានគ្រប់កងហ្នឹង ។

ប៊ុនថន : កាលហ្នឹងប្រធានកងអ្នកមីងឈ្មោះអីដែរ?

ភន : ប្រធានកងខ្ញុំពិបាកចុចឈ្មោះណាស់ ឈ្មោះច្រើនពេក មេកងធំផងកងតូចផងតាមកង នោះកងហារ កងរយ កងវរៈដល់នេះគេបញ្ជូនចុះម៉ោ ។

ប៊ុនថន : កាលហ្នឹងឆ្នាំប៉ុន្មានអ្នកមីងម៉ោបាត់ដំបង?

ភន : ខ្ញុំម៉ោបាត់ដំបង៧៨ ។

ប៊ុនថន : ៧៨?

ភន : ចា៎!ម៉ោ៧៨ ។ ៧៩ខ្ញុំរត់ចេញពីបាត់ដំបង ហ្នឹងម៉ោបាត់ដំបងហ្នឹងនៅរោងចក្រៗបាន ប៉ុន្មានខែ ដល់៧៩ខ្ញុំរត់ រត់ទៅដីថៃ ។

ប៊ុនថន : នៅរោងចក្រអីវិញអ្នកមីង?

ភន : នៅរោងចក្របាវ ដូនទាវនោះ ។

ប៊ុនថន : បាទ!កាលហ្នឹងមីងមាននៅខាងយុទ្ធនារីទេ?

ភន : អត់ទេ!នៅកុមារ ។

ប៊ុនថន : ហេតុអីបានរត់ទៅថៃ?

ភន : រត់ទៅយួនចូលស្រុកនោះ ។

ប៊ុនថន : អូ!៧៩?

ភន : ចា៎!៧៩មិនយួនចូលស្រុកៗមិនរត់ទៅដីថៃ ដល់រត់ទៅដីដល់ចេញពីដីថៃម៉ោបានធ្វើ សង្គ្រាមហ្នឹង កើតជានារីគេទៅ ដឹកជញ្ជូនជនាន់យួនហ្នឹង ដឹកជញ្ជូនរបួតទៅ ប៉ុនខ្ញុំបាន ប្ដីនៅ៩០នេះហ្នឹងៗនេះទេ បានប្ដីចប់សង្គ្រាមអស់រលីង ។

ប៊ុនថន : ហើយមីងទៅថៃហ្នឹងឆ្នាំប៉ុន្មានបានចូលម៉ោវិញ?

ភន : ចូលបាន១ឆ្នាំៗយើងដកម៉ោនៅអីដីយើងនេះវិញ ។

ប៊ុនថន : បាទ!ចូលម៉ោនៅដីយើងហ្នឹង នៅណាវិញ?

ភន ៖ នៅម៉ាជួរ៦៩ ម្តុំបរឡាង ។

ប៊ុនថន ៖ បរឡាងហ្នឹងនៅ?

ភន ៖ បរឡាងនៅសំឡូត ។

ប៊ុនថន ៖ នៅហ្នឹងគេហៅអីវិញ៦៩?

ភន ៖ ៦៩ ។

ប៊ុនថន ៖ ៦៩ហ្នឹងគេសំដៅលើអីវិញមីង?

ភន ៖ ៦៩ហ្នឹងគេដាក់ឈ្មោះអញ្ចឹងហ្មង១ ៦៩ម្តុំឃ្លាំងណយអីហ្នឹង ឃ្លាំងណយ បរឡាង ម៉ាជួរកន្លែងគេធ្វើត្បូងម៉ាជួរហ្នឹង ។

ប៊ុនថន ៖ ជិតៗប៉ៃលិនដែលមីង?

ភន ៖ ចា៎!ផ្លូវទៅប៉ៃលិន ជិតៗប៉ៃលិនដែរ ។

ប៊ុនថន ៖ ហើយមីងនៅជាមួយអ្នកណាពេលម៉ោនៅ៦៩ហ្នឹង?

ភន ៖ តាដន មេកង ។

ប៊ុនថន ៖ គាត់មានត្រកូលអី?

ភន ៖ ត្រកូលគាត់មិនដឹងអីដន ខ្ញុំអត់ស្គាល់ត្រកូលគាត់ផង ស្គាល់តែពូដនអញ្ចឹង ។

ប៊ុនថន ៖ គាត់កាន់ខាងអីវិញមីង?

ភន ៖ កាន់រូម កងម៉ាដឹកជញ្ជូនយើងហ្នឹងគាត់កាន់រូម ។

ប៊ុនថន ៖ គេហៅវរៈ?

ភន ៖ ហ្នឹងហើយវរៈសេនាតូច ។

ប៊ុនថន ៖ លេខប៉ុន្មាន?

ភន ៖ កង០១ ។

ប៊ុនថន ៖ បាទ!ម៉ាក្រុមមីងហ្នឹងសុទ្ធតែស្រីៗទាំងអស់មីង?

ភន ៖ មានៗប្រុសដែរ ក្នុងមន្ទីរគេហ្នឹងមានប្រុសទៅដល់ហ្នឹងមានមន្ទីរគាត់គេហៅមន្ទីរដើម មានប្រុសៗមួយក្រុម ។

ប៊ុនថន ៖ ចុះ០១មីង មន្ទីរ០១?

ភន ៖ ចា៎!ឈ្មោះគេដាក់០១ហ្នឹងគេដាក់ឈ្មោះគាត់ទេ ។

ប៊ុនថន ៖ តាដន ហ្នឹងគាត់ម៉ោពីខេត្តណាដែរមីង?

ភន ៖ តាដន គាត់នៅតាកែវ ។

ប៊ុនថន ៖ តែគាត់មានគ្រួសារដែរកាលហ្នឹង?

ភន ៖ មាន ។

ប៊ុនថន ៖ គ្រួសារគាត់នៅតាកែវដែរ?

ភន ៖ ចា៎!ប្ដីប្រពន្ធគាត់មាន កូនគាត់មាន ។

ប៊ុនថន ៖ ប្រពន្ធគាត់នៅធ្វើអីដែរកាលហ្នឹង?

ភន ៖ ប្រពន្ធគាត់អត់ធ្វើអីផង ។

ប៊ុនថន ៖ ដឹកជញ្ជូនដូចមីងដែរ?

ភន ៖ អត់ដឹកជញ្ជូនទេ តែគ្រាន់តែថាគេនៅ ប្ដីគេក៏គាត់មិនទៅណាដែរ គេគ្រាន់តែដឹកនាំយើងហ្នឹង ពេលយើងទៅដឹកជញ្ជូនឲ្យកងទ័ពអញ្ចឹងទៅគាត់ទៅមួងម្កាលអីហ្នឹង ទៅជាមួយយើងមួងម្កាល ។

ប៊ុនថន ៖ ដឹកទៅឲ្យខាងណាវិញអ្នកមីង?

ភន ៖ ដឹកទៅឲ្យកងទ័ព ។

ប៊ុនថន ៖ កងទ័ពហ្នឹង?

ភន ៖ កងទ័ពខ្មែរក្រហមយើងហ្នឹង ។

ប៊ុនថន ៖ បាទ!ប៉ុន្តែដឹកឲ្យកងពលលេខប៉ុន្មានៗអញ្ចឹង?

ភន ៖ ដឹកឲ្យខាងកងពល គេហៅអីគេកាលហ្នឹង វរៈ៥វរៈ៦គេហៅសុទ្ធតែវរៈ ដឹកឲ្យកងតា ទឹម មិនដឹងគេហៅលេខអីគេទេកាលហ្នឹង ។

ប៊ុនថន ៖ តាទឹមហ្នឹងគាត់?

ភន ៖ តាទឹមហ្នឹងគាត់កាន់ទ័ព ។

ប៊ុនថន ៖ ប្រធានគេ?

ភន ៖ ប្រធានកងទ័ព ។

ប៊ុនថន ៖ ឈ្មោះអីទឹមគាត់?

ភន ៖ ខ្ញុំអត់ស្គាល់គេទាំងអស់ មិនដឹងឈ្មោះអីស្គាល់តែមួយៗហ្នឹងត្រកូលគាត់អត់ស្គាល់ ។

ប៊ុនថន ៖ ចុះនៅលើតាដន ហ្នឹងមានអ្នកណាធំៗជាងគាត់ទេ?

ភន ៖ មាន ។

ប៊ុនថន ៖ ពីណាខ្លះមីង?

ភន ៖ លើតាដន មានតាម៉េត ។

ប៊ុនថន ៖ គាត់ស៊ូ ម៉េតហ្នឹងមីង?

ភន ៖ ចា៎!តាម៉េត លើគេហ្នង ។

ប៊ុនថន ៖ តាម៉េត ហ្នឹងគាត់កាន់ខាង?

ភន ៖ កាន់រួមទាំងអស់ ។

ប៊ុនថន ៖ គាត់កាន់រួមហ្នឹងគាត់មានកងពលលេខប៉ុន្មានកាលហ្នឹង?

ភន ៖ អារឿងកងទ័ពខ្ញុំអត់សូវដឹងដែរ មិនដឹងជាកងពលលេខប៉ុន្មានៗខ្ញុំអត់សូវដឹងដែរ ។

ប៊ុនថន ៖ បាទ!ប៉ុនដឹងតាម៉េត ហ្នឹងគាត់គ្រប់គ្រងលើតាដនទៀត?

ភន ៖ ចា៎! គាត់គ្រប់គ្រងលើគេទាំងអស់ តាម៉េតហ្នឹងពុថានៅសំឡូត ។

ប៊ុនថន ៖ ចុះមីងដែលជួបគាត់ទេកាលហ្នឹង?

ភន ៖ អត់ដែលជួបគាត់ដងឥឡូវ ។

ប៊ុនថន ៖ កាលជំនាន់ហ្នឹងមានដែលជួបគាត់ទេ?

ភន ៖ កាលជំនាន់ណា?

ប៊ុនថន ៖ ជំនាន់មីងបែកហើយ?

ភន ៖ អត់!ខ្ញុំចេញពីហ្នឹងម៉ោ ដុតរហូតអត់ដែលជួបគាត់រលីង ។

ប៊ុនថន ៖ ប៉ុនមិនដឹងឈ្មោះគាត់មីង?

ភន ៖ ចុះកាលដែលនៅកងទ័ព នៅឯសំឡូតហ្នឹង ។

ប៊ុនថន ៖ បាទ!ប៉ុនពេលនោះមីងដែលជួបគាត់ទេ កាលនៅសំឡូត?

ភន ៖ ដើរជាមួយតែគាត់ដែលហ្នឹង ។

ប៊ុនថន ៖ អ្ហូ!ដើរជាមួយគ្នា?

ភន ៖ ចា៎!ដើរជាមួយតែគ្នាដែលហ្នឹង គាត់ទៅយើងទៅដែលហ្នឹង គាត់ស្គាល់កូនចៅដែល ហ្នឹង ។

ប៊ុនថន ៖ អញ្ចឹងគាត់នៅស្គាល់មីង បើឥឡូវរាល់ថ្ងៃនេះ?

ភន ៖ ឥឡូវរាល់ថ្ងៃនេះគាត់អត់ស្គាល់ទេ គាត់ ទ័ពវាច្រើន នារីដឹកជញ្ជូនក៏វាច្រើនដល់អញ្ចឹង គាត់អត់ស្គាល់ទេ ប៉ុនយើងស្គាល់គាត់ ។

ប៊ុនថន ៖ គាត់ស្រុកកំណើតនៅណាដែរតាម៉េត?

ភន ៖ តាម៉េត មិនដឹងស្រុកកំណើតគាត់នៅណា ខ្ញុំអត់ស្គាល់ដែរ ប៉ុនទំនងពេលគាត់និយាយ ដូចនៅកំពង់ឆ្នាំងអញ្ចឹង ដូចសម្លេងគាត់និយាយដូចកំពង់ឆ្នាំង ។

ប៊ុនថន ៖ ប៉ុនគាត់មានគ្រួសារឬនៅកាលហ្នឹង?

ភន ៖	មានកូនចៅគាត់មោ៉នៅនេះ ។

ប៊ុនថន ៖	កាលហ្នឹងកូនគាត់ប៉ុន្មាននាក់ម៉ោនៅនេះ?

ភន ៖	កូនគាត់មិនដឹងប៉ុន្មាននាក់ដែរ ។

ប៊ុនថន ៖	ចុះគ្រួសារគាត់ម៉ោពីខាងណាដែរ?

ភន ៖	គ្រួសារៗអត់ដឹងម៉ោពីខាងណាផង ប៉ុន្តែដឹងឈ្មោះ ស្គាល់ឈ្មោះ ។

ប៊ុនថន ៖	ឈ្មោះអីដែរមីង?

ភន ៖	ឈ្មោះ យាយវន ។

ប៊ុនថន ៖	ហើយដើរជាមួយគាត់ហ្នឹងយ៉ាងម៉េចដែរ ដូចថាគាត់រុះរាយ?

ភន ៖	អត់អីទេ! គាត់ស្លូតហ្នឹង ស្រួលស្លូតបូត ប៉ុនមេគេធំៗមានច្រើនដែរ មានតាម៉ារយៗ ប៉ុនគេដាក់ងារគាត់ឈ្មោះតាផល ហ្នឹងជាកងទ័ពដែរ ប្រធានកងទ័ពដែរ បន្ទាប់ៗគ្នាគាត់ហ្នឹង ។

ប៊ុនថន ៖	បន្ទាប់គាត់ឬក៏ធំជាង?

ភន ៖	បន្ទាប់គាត់ ។

ប៊ុនថន ៖	តាម៉ារយ?

ភន ៖	ចា៎!តាម៉ារយហ្នឹងឈ្មោះ តាផល ។

ប៊ុនថន ៖	មានចាំត្រកូលអីផលទេ?

ភន ៖	អត់!ខ្ញុំអត់មានចាំទេមេៗនោះ អត់មានស្គាល់ត្រកូលគេទេ ដឹងតែឈ្មោះគាត់ ។

ប៊ុនថន ៖	ម៉ាកងមីងហ្នឹងប៉ុន្មាននាក់ ដឹកជញ្ជូន?

ភន ៖	កងខ្ញុំហ្នឹងច្រើនណាស់ ចុះយើងកងយើងនៅបែកគ្នា ឧទាហរណ៍ថា កងខ្ញុំ ម៉ាកងហានៅនេះ ម៉ាកងហានៅនោះ ម៉ាកងហានៅនោះទៀតសរុបកងរយទៀត គេសុទ្ធកាន់កងគេនោះ ដល់អញ្ចឹងយើងស្គាល់អត់អស់ដែរ ។

ប៊ុនថន ៖	អញ្ចឹងមីងនៅម៉ាកងមីងហ្នឹងប្រហែលប៉ុន្មាននាក់?

ភន ៖	ម៉ាកងខ្ញុំមាន៥ក្រុមៗ ម៉ាក្រុមមាន១២នាក់ អាហ្នឹងគេហៅម៉ាកងតូច ។

ប៊ុនថន ៖	បាទ!៦០នាក់អីអញ្ចឹងទៅ?

ភន ៖	ចា៎!៦០នាក់ ឬ៥០នាក់អីអញ្ចឹងទៅម៉ាកងតូច ។

ប៊ុនថន ៖	ហើយអ្នកមីងធ្វើការអីខ្លះនៅហ្នឹង?

ភន ៖	កាលនៅដឹកជញ្ជូនកាលហ្នឹង?

ប៊ុនថន ៖ បាទៗ!

ភន ៖ ខ្ញុំអត់ធ្វើអីផង កូនយើងធម្មតាកូនចៅគេធម្មតាអត់មាន ប្រធានក្រុមអត់មាន ។

ប៊ុនថន ៖ អត់ទេ!យាយថាការងារប្រចាំថ្ងៃ?

ភន ៖ អ្ហូ!ប្រចាំថ្ងៃអត់ធ្វើអីផង ។

ប៊ុនថន ៖ មីងដឹកដួចថាជញ្ជូន?

ភន ៖ ដឹក ពេលថ្ងៃណាដែលទ័ពនៅខាងមុខខ្វះគ្រាប់ ខ្វះស្បៀងអញ្ចឹងទៅ គេស្រែហៅតាមគេហៅទូរលេខ កាលហ្នឹងយើងប្រើទូរលេខ ហ្នឹងគេហៅតាមទូរលេខហ្នឹងម៉ោឲ្យដឹកជញ្ជូនទៅ ដឹកជញ្ជូនរៀបចំខ្លួនទៅព្រឹប ។

ប៊ុនថន ៖ មានដឹកជញ្ជូនអីខ្លះកាលហ្នឹង?

ភន ៖ គេមានគ្រាប់ មានអង្ករ មានចំណីឲ្យកងទ័ពនោះស្បៀង គ្រាន់តែគ្រាប់បន្ទាប់បន្សំមានតែមួយអីវ៉ាន់ទេ ដឹកជញ្ជូនគ្រាប់អញ្ចឹងទៅគ្រាប់ទាំងអស់ទេ ។

ប៊ុនថន ៖ គ្រាប់មានគ្រាប់អីមីង មានដឹងទេ?

ភន ៖ មានគ្រាប់ប៉េ គ្រាប់ឡង់សំប៉ែត មានគ្រាប់អាកា អៀវកែងអីមានសព្វ វ៉ាន់ធីណៃ វ៉ាន់ធីធូ ដឹកជញ្ជូនស្គាល់គ្រាប់ទាំងអស់ប៊ុន ។

ប៊ុនថន ៖ ប៊ុនមីងចេះប្រើចេះបាញ់ទេ?

ភន ៖ កាលជំនាន់៧៩ បាញ់ ។

ប៊ុនថន ៖ ចេះដែរ?

ភន ៖ ចេះ ។

ប៊ុនថន ៖ មីងហាត់ឬក៏?

ភន ៖ ហាត់ៗ គេបង្ហាត់យើងគេដាក់ដូចដាក់បាវាំងគេប៉ុនេះទៅ គេដាក់បណ្តោះកណ្តាលហ្នឹងឲ្យយើងស្ទាបចំប្រហោះកណ្តាលហ្នឹង បើយើងបាញ់ចំប្រហោះកណ្តាលហ្នឹងគេថាយើងលេខ១ហើយ យើងបាញ់ត្រង់ ។

ប៊ុនថន ៖ ចុះមីងបាញ់ត្រង់ទេមីង?

ភន ៖ ខ្ញុំអត់!អត់សូវចេះបាញ់គេ ។

ប៊ុនថន ៖ ប៊ុនដូចរៀនអញ្ចឹងអត់ភ័យទេមីង?

ភន ៖ ភ័យដែលហ្នឹង ឥឡូវភ័យៗ បើសិនព្រួសរកាំភ្លើងក្តុងក្តាំងអីភ័យដាងគេទៀត ។

ប៊ុនថន ៖ បាទ!ប៊ុនសម័យនោះអត់មានភ័យទេមីង?

ភន ៖ អត់មានភ័យទេ គ្រាប់ផ្លោងធ្លាក់នៅក្បែរៗហ្នឹងអត់មានភ័យទេ ។

ប៊ុនថន ៖ ចុះស្បៀងមានអីខ្លះដឹកទៅ?

ភន ៖ ស្បៀងមានអង្ករ មានម្ហូបដូចជាត្រីខ កាលហ្នឹងយើងចិនជំនួយមានត្រីខ មានសុទ្ធតែកំប៉ុងទាំងអស់ៗ ។

ប៊ុនថន ៖ ប៉ុនហូបគ្រប់គ្រាន់ទេមីង?

ភន ៖ គ្រប់គ្រាន់ ហូបអត់អស់ផង មានតែហូបសល់ផងកាលជំនាន់ហ្នឹងនោះ ហើយយើងអត់ចាយលុយផងកាលហ្នឹង ចាយតែរបស់បើក ហូបតែរបស់បើកហ្នឹង ។

ប៊ុនថន ៖ ចុះជំនួយក្រៅពីចិនមានជំនួយម៉ោពីណាទៀតមីង?

ភន ៖ អត់ដឹង!ដឹងតែរបស់ចិនមួយ ។

ប៊ុនថន ៖ ម៉េចបានមីងដឹងថារបស់ចិនមីង?

ភន ៖ ចុះបើគេថារបស់ចិន គេថាជំនួយម៉ោពីចិន ហើយបើអក្សរអីសុទ្ធតែចិនទាំងអស់ ។

ប៊ុនថន ៖ ហើយមីងដឹកទៅសមរភូមិ ដឹកទៅដល់ៗកន្លែងគេវ៉ៃគ្នាហ្មងមីង?

ភន ៖ ចា៎!ដល់សមរភូមិគេវ៉ៃគ្នាហ្មង ។

ប៊ុនថន ៖ ទៅដឹកម្តងប៉ុន្មាននាក់មីង?

ភន ៖ ទៅច្រើនណាស់ រាប់ពាន់នាក់ ។

ប៊ុនថន ៖ ហ្នឹងគេដឹក គេចែកម៉េចវិញមីង?

ភន ៖ យើងដើរទៅគេត្រៀម គេយាមផ្លូវឲ្យយើង មានកងទ័ពគេការពារផ្លូវឲ្យយើង យើងដើរទៅតាមផ្លូវទៅ អត់មានជួបខបសគ្គអីទេ ។

ប៊ុនថន ៖ អ្ហូ!មានដឹកឡានមីង?

ភន ៖ អត់ទេ!ស្ពាយនឹងខ្នងៗ បើថានៅកងអីគេនោះគេស្ពាយឡើងលិចៗក្បាល សាក់កាដូរចិនអាធំៗហ្នឹង ស្ពាយឡើងលិចៗក្បាល ទៅម្តងម៉ាអាទិត្យគេទៅម៉ាដើងហ្នឹងមានតែ ២អាទិត្យទៅម៉ាអាទិត្យ ។

ប៊ុនថន ៖ ទៅហ្នឹងឆ្ងាយទេមីង ពីកន្លែង?

ភន ៖ ឆ្ងាយៗណាស់ ដេកផ្លូវច្រើនយប់ណាស់ ឡើងភ្នំចុះភ្នំ ដល់ថ្នាក់ទាញវល្លិ៍ឡើងក៏មានកិលគូទក៏មាន ។

ប៊ុនថន ៖ ទៅហ្នឹងដូចថាម៉ាកងមីងហ្នឹងមានប្រុសមានស្រីទេមីង?

ភន ៖ មានៗស្មើគ្នា គេការពារស្មើគ្នា មានស្រីមានប្រុសស្មើគ្នា ។

ប៊ុនថន :	បាទ! ហើយដើរទៅមានដែលប៉ះគ្រោះថ្នាក់មានអីទេមីង?

ភន :	មានដែរ មានដូចយើងទៅជួបឧបសគ្គមានយួនវាកាត់ផ្លូវអីអញ្ចឹងទៅ បកម៉ោវិញមានជាន់មីងជាន់អីអញ្ចឹងទៅ ដាច់ជើងមានដែរនារីៗ ខ្លះហ្នឹងក៏ស្លាប់ទៅ ខ្លះក៏នៅរស់ទៅ មានជួបឧបសគ្គច្រើនដែរ ។

ប៊ុនថន :	មីនហ្នឹងជាន់ខាងណាអ្នកដាក់មីង?

ភន :	ដាក់មិនដឹងជាខាងណាខាងណី មិនជាខាងទាហានយួន ក៏មិនដឹងជាខាងទាហានយើង ពេលសមរភូមិយើងវ៉ៃដេញវាទៅ វាមិនថយបាត់ទៅយើងចូលទៅ ដល់ពេលវាដេញយើងម៉ោវិញម៉ោ យើងថយម៉ោ ជួនអីទៅក៏វាចេញទៅវិញវាដាក់ឲ្យយើងក៏មាន អញ្ចឹងវាច្របូកច្របល់គ្នា ។

ប៊ុនថន :	អញ្ចឹងមីងនៅកងដឹកជញ្ជូនហ្នឹងរហូតដល់ឆ្នាំណា?

ភន :	ខ្ញុំនៅកងដឹកជញ្ជូនតាំងពី៧៩ហ្នឹងមក រហូតដល់៩៦ ។

ប៊ុនថន :	៩៦?

ភន :	ចា៎! ៩៦ខ្ញុំការគ្រួសារហ្នឹងឈប់នៅតាមកង ។

ប៊ុនថន :	បាទ! ប៉ុនមីងអត់មានផ្លាស់ប្តូរកន្លែងទេ?

ភន :	អត់! នៅតែសំឡូតហ្នឹង ម៉ាកន្លែងហ្នឹង គេប៉ៃលិនគេនៅប៉ៃលិន ខ្ញុំនៅសំឡូតនៅសំឡូត ទីមផ្លាស់ម៉ោនៅហ្នឹង នេះគេហៅផ្លូវ៥៦ ។

ប៊ុនថន :	ផ្លូវ៥៦ហ្នឹង កាលហ្នឹងពីណាអ្នកគ្រប់គ្រងមីង?

ភន :	យួន ខាងយួនគេហៅ«ក៥» ខ្មែរយើងប្រជាជនខ្មែរយើងហ្នឹង តែទាហានខ្មែរហ្នឹងគេហៅ«ក៥» បើខ្មែរក្រហមគេហៅទាហានខ្មែរ ខាងខ្ញុំខ្មែរក្រហមខ្ញុំហៅខាងគេនោះហ្នឹង ទាហានខ្មែរ ទាហានយួនទាហានខ្មែរ ។

ប៊ុនថន :	ចុះមីងនៅនោះអញ្ចឹងមានផ្លាស់ប្តូរមេអី?

ភន :	អត់ៗផ្លាស់ផង ។

ប៊ុនថន :	តាដនហ្នឹងគាត់នៅរហូត?

ភន :	នៅរហូតទាល់ខ្ញុំចេញម៉ោនេះម៉ោ ដល់ខ្ញុំចេញម៉ោនេះផុតម៉ោមិនដឹងជាគាត់នៅណា ។

ប៊ុនថន :	ចុះគ្រួសារអ្នកមីង?

ភន :	គ្រួសារខ្ញុំស្លាប់នៅតាពាន់ ដាច់ជើងជាន់មីនវ៉ៃជាមួយយួនហ្នឹង ។

ប៊ុនថន :	អញ្ចឹងពាល់ថ្ងៃនេះគ្រួសារក្រោយទេ?

ភន ៖ ចា៎ៗ ! គ្រួសារក្រោយនេះទឹមយកយើងឆ្នាំ២០០០នេះហ្នឹង ។

ប៊ុនថន ៖ គ្រួសារមុនហ្នឹងគាត់នៅកងជាមួយមីងដែរ?

ភន ៖ ចា៎ ! គាត់ទឹមម៉ោពីទាហានខ្មែរដែរ ។

ប៊ុនថន ៖ គាត់ម៉ោក្រោយ៧៩នេះ គាត់ម៉ោរត់ចូលខាងនេះ?

ភន ៖ ចា៎ ! ហ្នឹងហើយគាត់រត់ម៉ោខាងនេះ ដល់ហើយក៏ខ្ញុំបានគ្នាទៅ ។

ប៊ុនថន ៖ គាត់អ្នកស្រុកណាដែរ?

ភន ៖ គាត់អ្នកខេត្តកណ្ដាល តែដល់បានប្ដីប្រពន្ធទៅខ្ញុំអត់ដែលស្គាល់ផ្ទះគេ ម៉ែឪគេអត់ស្គាល់ទាល់តែគេស្លាប់ទៅ អត់ស្គាល់រហូតដល់ឥឡូវហ្នឹង នៅខាងកើតភ្នំពេញហ្នឹង ស្រុកមុខកំពូល ខេត្តកណ្ដាល ស្រុកមុខកំពូល ភូមិព្រៃសំបួរ ។

ប៊ុនថន ៖ ឃុំអីវិញមីង?

ភន ៖ ឃុំមិនដឹងឃុំអីខ្ញុំអត់ស្គាល់ អត់បានសួរឃុំគេដឹងតែស្រុកមុខកំពូល ភូមិព្រែកសំបួរគេថានៅខាងកើតភ្នំពេញ បងថ្លៃខ្ញុំមួយគេថាឈ្មោះ សុខ នៅខាងកើតភ្នំពេញ តែគាត់ក៏អត់ស្គាល់ខ្ញុំ ខ្ញុំក៏អត់ស្គាល់គាត់ដាច់រយៈគ្នាទៅ ។

ប៊ុនថន ៖ កាលហ្នឹងមូលហេតុអីបានគាត់រត់ម៉ោខាងមីងវិញ?

ភន ៖ ដែលយើងអំពាវនាវឲ្យចុះម៉ោ ខាងខ្មែរក្រហមអំពាវនាវឲ្យចុះម៉ោ ដល់ចុះម៉ោទៅគេចុះម៉ោសារភាពទៅក៏យើងស្រឡាញ់គ្នាដូចតែបងប្អូនអញ្ជឹងទៅ ។

ប៊ុនថន ៖ បាទ ! ហើយអ្នកមីងរៀបការជាមួយគាត់ហ្នឹង ស្រឡាញ់គ្នាឬមួយខាងអង្គការគេរៀបចំឲ្យមីង?

ភន ៖ ហ្នឹងហើយខាងមេគេរៀបចំឲ្យ ។ មេខ្ញុំក៏រៀបចំឲ្យដែរ មេគេក៏រៀបចំឲ្យដែរ ។

ប៊ុនថន ៖ កាលហ្នឹងគាត់នៅខាងអីវិញមីង គ្រួសារមីង?

ភន ៖ ខាងកងទ័ពហ្នឹងអី?

ប៊ុនថន ៖ បាទ !

ភន ៖ ខាងពិសេស ។

ប៊ុនថន ៖ កងពិសេសហ្នឹងមានលេខមានអីទេមីង?

ភន ៖ អត់ ! អត់ចាំងឈ្មោះទៀតឥឡូវហ្នឹង អត់មានឈ្មោះស៊ីប្រាក់ខែគេទៀតឥឡូវហ្នឹង ។ ងាប់ឥតប្រយោជន៍ហើយអត់មានឈ្មោះស៊ីប្រាក់ខែគេទៀត ។

ប៊ុនថន ៖ កងពិសេសហ្នឹងគាត់នៅក្រោមពីណាវិញអ្នកមីង?

ភន ៖ មិនដឹងជាគេនៅខាងណាទេ កងគេ បញ្ញាការគេខ្ញុំដឹងថាឈ្មោះ តាមុត ។

ប៊ុនថន ៖ គាត់អីមុត ត្រកូល?

ភន ៖ មិនដឹងអីមុត អត់ស្គាល់ៗទេ ។ បើអ៊ំមិញគាត់ប្រហែលជាស្គាល់ ។

ប៊ុនថន ៖ តាមុតហ្នឹងគាត់គ្រប់គ្រងនៅខាងណាវិញមីង? ?

ភន ៖ នៅសំឡូតដែលហ្នឹង គាត់ខ្វះភ្នែកម្ខាងដែលហ្នឹងតាមុត ។

ប៊ុនថន ៖ អ៊ូ!មិនមែនឈ្មោះ មាស មុត ទេមីង?

ភន ៖ ដឹងម៉េចដឹងត្រកូលគាត់ឈ្មោះអី ។ មិនដឹងមាស មុត មិនដឹងអី ។

ប៊ុនថន ៖ គាត់ធំដែរអ្នកមីង?

ភន ៖ ធំដែរ មេទាហានដែរ ។

ប៊ុនថន ៖ គាត់ថ្នាក់ស្មើ ស៊ូ ម៉េតអីទេ?

ភន ៖ អត់ទេៗ ។

ប៊ុនថន ៖ តូចជាង?

ភន ៖ កងតូចកងហាអីហ្នឹង គាត់ទាបបំផុតហ្នឹង ។

ប៊ុនថន ៖ ជាកងហាទេ?

ភន ៖ ចាំ!

ប៊ុនថន ៖ មីងបានគាត់ឆ្នាំប៉ុន្មានកាលហ្នឹង?

ភន ៖ បានប្ដីខ្ញុំមុន?

ប៊ុនថន ៖ បាទ!

ភន ៖ បានឆ្នាំ៩៦ ។ ៩០ប៉ុន្មានទេយើងឈប់យើងចប់សង្គ្រាមហ្នឹង យើងត្រូវរូវគ្នា ។

ប៊ុនថន ៖ ៩៦មីង?

ភន ៖ ៩៦ហ្នឹងខ្ញុំការ៩៦ដែរ ។

ប៊ុនថន ៖ កាលហ្នឹងមីងអត់ទាន់ម៉ោនៅហ្នឹងទេ?

ភន ៖ នៅ ។

ប៊ុនថន ៖ នៅសំឡូតនោះទេ?

ភន ៖ ចាំ! នៅសំឡូតបានកូន២ បានម៉ោនេះ ។

ប៊ុនថន ៖ បាទ!កាលហ្នឹងគាត់ស្លាប់ឬនៅមីង?

ភន ៖ នៅៗ ម៉ោស្លាប់នេះស្លាប់តាពណ៌នេះ ។

ប៊ុនថន ៖ តាពណ៍នេះ?

ភន ៖ នេះតាពណ៍យើងនេះ ។

ប៊ុនថន ៖ បាទ!កាលហ្នឹងវៃគ្នាមីង?

ភន ៖ វៃៗគ្នា ។

ប៊ុនថន ៖ វៃខ្លាំងទេមីង?

ភន ៖ ខ្លាំងដែរហ្នឹង ។

ប៊ុនថន ៖ វៃជាមួយពីណាគេ?

ភន ៖ វៃជាមួយខ្មែរគ្នាឯងហ្នឹង ។

ប៊ុនថន ៖ មីងគេបញ្ជូនយកម៉ោច្រើនទេពីនោះម៉ោ?

ភន ៖ ច្រើនដែរ ។

ប៊ុនថន ៖ ប៉ុន្មានមីងមានចាំទេ ប៉ុន្មានគ្រួសារឬប៉ុន្មាននាក់មីង?

ភន ៖ ខ្ញុំអត់ចាំគ្រួសារគេផង ប៉ុនកង់ទ័ពមិនដឹងជាប៉ុន្មានគ្រួសារគេបញ្ជូនម៉ោនេះ ។

ប៊ុនថន ៖ គេបញ្ជូនម៉ោនេះ មីងម៉ោដល់ដំបូងយ៉ាងម៉េចដែរមីង? ដូចថាមានផ្ទះប្រជាជនរស់នៅទេឬក៏ជាព្រៃទេមីង?

ភន ៖ ព្រៃសុទ្ធហ្នឹង យើងម៉ោវែកធ្វើផ្ទះនៅហ្នឹង ព្រៃស្រោងសុទ្ធតែព្រៃហាត់ព្រៃហោងហ្នឹងម៉ោវែកប្រឡង់ធ្វើផ្ទះនៅ ។

ប៊ុនថន ៖ ចុះម៉ោខាងប្រមោយនោះអត់មានមនុស្សម៉ោនៅទេ?

ភន ៖ អត់ដូចគ្នា ។

ប៊ុនថន ៖ គេវាលហើយ?

ភន ៖ គេម៉ោមុនៗគ្រាន់បានវាលខ្លះហើយ គេម៉ោមុនខ្ញុំ បានវាលតិចៗហើយខ្ញុំម៉ោក្រោយ គេមិនម៉ោក្រោយគ្នាប៉ុន្មានទេ ម៉ាឆ្នាំអីហ្នឹង ។

ប៊ុនថន ៖ ប៉ុនផ្លូវអីមានទេ កាលហ្នឹង?

ភន ៖ ផ្លូវមានផ្លូវ៥៦ហ្នឹងទៅ ផ្លូវលំទេអត់មានអញ្ចេះទេ យើងដើរកាត់តែព្រៃហ្នឹង ។

ប៊ុនថន ៖ អត់សូវមានឡានបើកទេ?

ភន ៖ អត់ៗមានទេ ម៉ោដល់យើងបើថាយើងទិញអង្ករ ដូចទិញស្ករស ប៊ិចេងយើងទិញម៉ោច្រើនៗហើយស្រេចម៉ង បើអត់មានផ្លូវទៅណា ទៅពោធិ៍សាត់អីទៅអត់រួចណា៎ ។ ទៅអត់កើតទេកាលហ្នឹងអត់មានឡានរត់ទេ ។

ប៊ុនថន : ចុះទិញ ឬក៏ខាងអង្គការបើកឲ្យអ្នកមីងកាលហ្នឹង?

ភន : ទិញស្អីគេ?

ប៊ុនថន : ចង់សួរថាមីងទិញរបស់របរហូបចុក បិចេងអីហ្នឹងខាងអង្គការបើកឲ្យមីង?

ភន : អត់ទេទិញ កាលហ្នឹងប្រើលុយហើយ ។

ប៊ុនថន : ប្រើលុយហើយ?

ភន : ចាំ!

ប៊ុនថន : ប៉ុនមានអង្គការខបត្តមអីដែរកាលហ្នឹង?

ភន : ទឹមអង្គការខបត្តមដែលយើង ។

ប៊ុនថន : ខាងខ្មែរក្រហមមាននៅខបត្តមទេមីង?

ភន : អត់ៗ!

ប៊ុនថន : ចុះមីងគេបញ្ជូនម៉ោនេះគេបែងចែកម៉េចវិញមីង?

ភន : គេអត់មានបែងចែកអីផង គេគ្រាន់តែបញ្ជូនម៉ោតាមដែលប្តីយើងម៉ោធ្វើការនៅកោះ កុង កាលហ្នឹងប្តីមិននៅធ្វើការនៅកោះកុង ។

ប៊ុនថន : ប៉ុនគាត់នៅធ្វើការខាងខ្មែរក្រហមនៅឡើយទេ?

ភន : ចាំ!នៅខាងខ្មែរក្រហមនៅឡើយទេ ខ្មែរក្រហមខាងនោះនៅផ្សេង ខាងនេះនៅផ្សេង ប៉ុន្តែបើយើងទៅរកស៊ីខាងហ្នឹងអត់អីទេ ។ យើងដូចទៅត្រួតពិនិត្យគេអញ្ចឹងទៅណាំ ព្រោះយើងបន្ទាប់ខ្មែរក្រហមនោះ ឲ្យណាខាងក្នុងៗគេខ្លាច ។

ប៊ុនថន : ហើយអ្នកមីងម៉ោខាងភូមិនេះ ខ្មែរក្រហមគេចាត់ម៉ោទេ រៀបការជាមួយហ្នឹង?

ភន : ចាំ!

ប៊ុនថន : ចុះម៉ោដល់ហ្នឹងគេបែងចែកម៉េចវិញមីង បែងចែកឲ្យយើងនៅម៉េចវិញ?

ភន : គេបែងចែកឲ្យយើងនៅតាមស្ទឹងហ្នឹង បែងចែកដីគ្នានៅទៅ យើងវែកប្រឡង់ចែកដីគ្នា នៅទៅ ធ្វើផ្ទះនៅទៅ ។

ប៊ុនថន : យើងចាប់បានដីប៉ុន្មានយើង?

ភន : កាលហ្នឹងអត់ចាប់ផង កាលហ្នឹងយើងវែកនៅៗអាណាថាយកប៉ុន្មាន យកប៉ុនហ្នឹង ទៅ ។

ប៊ុនថន : បាទ! គេអត់មានកំណត់ឲ្យទេ?

ភន : អត់! អត់មានកំណត់ទេកាលហ្នឹងនោះ ។

ប៊ុនថន : ហើយរបបអីខាងខ្មែរក្រហមគេអ្នកបើកឲ្យ?

ភន : ខាងខ្មែរក្រហមចប់ហើយអត់មានអី ។

ប៊ុនថន : របបហូបចុក?

ភន : អត់មានបើកផង ។

ប៊ុនថន : បញ្ជូនម៉ោហ្នឹងអត់មានបើកទេ?

ភន : អត់! អ៊ូ!បើនៅជំរុំ គេបញ្ជូនម៉ោពីជំរុំម៉ោវិញ ។

ប៊ុនថន : អញ្ចឹងអ្នកមីងទៅជំរុំទៀត?

ភន : ចា៎! ខ្ញុំម៉ោនេះបានមួយឆ្នាំហើយ មិនទាហានចូលម៉ោទៀត ។

ប៊ុនថន : ទាហានខាងណា ទាហានខ្មែរក្រហមអី?

ភន : ទាហានខែរម៉ោពីក្នុង យួនអីហ្នឹង ។

ប៊ុនថន : បាទ! ម៉ោមីងរត់?

ភន : ចូលម៉ោខ្ញុំរត់ទៅដីថៃ រត់ទៅជំរុំៗបានមួយឆ្នាំបានខ្ញុំឡើងម៉ោហ្នឹងវិញ ។

ប៊ុនថន : ហើយអ្នកមីងទៅជំរុំណា ឈ្មោះអីវិញអ្នកមីង?

ភន : ជំរុំស្អីគេទេ គេហៅជំរុំអីទេខ្ញុំភ្លេចបាត់ហើយ មិនដឹងជំរុំអីគេទេខ្ញុំភ្លេចបាត់ហើយ ។ សាយខេ អ៊ូ!មុនដំបូងម៉ោពីសាយខេ សាយខេម៉ោៗជំរុំអ៊ើ!ភ្លេចអាជំរុំហឹងបាត់ហើយ មិនដឹងគេហៅជំរុំអីទេ ខ្ញុំភ្លេចបាត់ហើយ ។

ប៊ុនថន : បាទ! អញ្ចឹងពេលទាហានខាងក្នុងចូលម៉ោអត់មានវ៉ៃគ្នាមីង កាលហ្នឹង?

ភន : វ៉ៃៗទីមហ្នឹង អត់ទៅដល់នោះទេវ៉ៃទីមហ្នឹង ប្ដីគេទៅវ៉ៃទប់ត្រឹមហ្នឹងគេបញ្ជូនយើងទៅ ជំរុំ ។

ប៊ុនថន : ចុះវ៉ៃហ្នឹង មានវ៉ៃបែកខ្មែរក្រហមទេ?

ភន : វ៉ៃអត់ទេខ្មែរក្រហមចូល ចេះតែវ៉ៃយើងវ៉ៃនេះទៅ ចេះតែក្ដុងក្ដាំងៗអត់មានអីទៅ ដក ។

ប៊ុនថន : ខាងណាដកមីងខាងក្នុង?

ភន : ខាងក្រោយនេះដកអញ្ចឹងទៅ ។

ប៊ុនថន : បាទ! ហើយអ្នកមីងក៏រត់ទៅខាងជំរុំថៃ?

ភន : ចា៎!

ប៊ុនថន : ចុះកាលវ៉ៃហ្នឹងអ្នកណាអ្នកដឹកនាំវ៉ៃមីង ខាងខ្មែរក្រហម?

ភន : វ៉ៃឥឡូវហ្នឹងអី?

ប៊ុនថន : បាទ!វ៉ៃ៩៦ហ្នឹង ឆ្នាំកាលអ្នកមីងម៉ោ?

ភន : នេះវ៉ៃ វ៉ៃនៅលើ ។

ប៊ុនថន : អ្ហូ!គាត់ក្រុមប្រឹក្សាស្រុកហ្នឹងមីង?

ភន : នេះវ៉ៃ នៅកន្លែងនេះកន្លែងដើមពោធិ៍លើនេះ វ៉ៃនាំវ៉ៃ ។

ប៊ុនថន : កាលហ្នឹងគាត់អ្នក?

ភន : គាត់មេកងដែរ ។

ប៊ុនថន : មេកងពលដែរ?

ភន : មេកងអនុសេនាតូចអញ្ចឹងទៅណា៎ ។

ប៊ុនថន : អនុសេនាតូច?

ភន : ចា៎!

ប៊ុនថន : គាត់ឈ្មោះអីវ៉ៃមីង?

ភន : សឿន វ៉ៃ ។

ប៊ុនថន : សឿន វ៉ៃ គាត់នៅភូមិហ្នឹងដែរមីង?

ភន : នៅភូមិហ្នឹងដែលហ្នឹង តែឥឡូវគាត់លែងធ្វើអីកើតហើយ គាត់ជរាហើយ ។

ប៊ុនថន : គាត់ជាអ្នកដឹកនាំ?

ភន : គាត់អ្នកដឹកនាំវ៉ៃ ។

ប៊ុនថន : ចុះមេធំលើគាត់ទៀត?

ភន : មេធំលើគាត់ទៀតមិនដឹងខាងណា ។

ប៊ុនថន : ចុះកាលវ៉ៃហ្នឹងប្តីអ្នកមីងបានវ៉ៃដែរអ្នកមីង?

ភន : មានតែតា ដាន ។

ប៊ុនថន : គាត់ឈ្មោះអី ដាន មីង?

ភន : ខ្ញុំឮតែឈ្មោះ តាដាន ។

ប៊ុនថន : ស្រុកគាត់នៅហ្នឹងដែរអ្នកមីង?

ភន : អត់ទេ!តាដាន នៅនោះនៅបេះដូង តាដានមេកងធំនៅបេះដូងនោះណា?

ប៊ុនថន : ខ្ញុំអត់ស្គាល់ទេអ្នកមីង?

ភន : អញ្ចឹង ។

ប៊ុនថន : សព្វថ្ងៃនេះគាត់នៅណាអ្នកមីង?

ភន : សព្វថ្ងៃនេះមិនដឹងគាត់នៅណា អត់ដឹងផង ។

ប៊ុនថន : បាទ!អ្នកមីងពេលវ៉ៃហ្នឹងអ្នកមីងនៅហ្នឹង ឬក៏មីងរត់ទៅថៃ?

ភន ៖ អត់ទេ! ខ្ញុំនៅថៃនោះ ។

ប៊ុនថន ៖ គេបញ្ជូនឲ្យទៅថៃ ឬមួយកមីង?

ភន ៖ ចា៎! គេបញ្ជូនឲ្យទៅដីថៃ ។

ប៊ុនថន ៖ ចា៎!បញ្ជូនតែស្រីៗទេមីង?

ភន ៖ បញ្ជូនតែស្រីៗទេ ។

ប៊ុនថន ៖ ប្រុសៗឲ្យវៃនៅនេះ?

ភន ៖ ប្រុសៗបកម៉ោវៃនៅនេះវិញ គេទប់ទាហាននៅនេះវិញ ។

ប៊ុនថន ៖ គ្រួសារអ្នកមីងអីវៃនៅហ្នឹងដែរមីង?

ភន ៖ ចា៎! វៃស្លាប់នៅពណ៌ ។

ប៊ុនថន ៖ អញ្ចឹងពេលស្លាប់ហ្នឹងមីងទទួលដំណឹងពីគាត់ទេមីង?

ភន ៖ ទទួល គេប្រាប់ តែយកអត់បានសពទៀត ។

ប៊ុនថន ៖ ស្លាប់ច្រើនទេអ្នកមីងកាលហ្នឹងវៃ?

ភន ៖ អត់! ស្លាប់តែប្ដីខ្ញុំមួយ ។

ប៊ុនថន ៖ ចុះខាងក្នុងមានស្លាប់ទេ?

ភន ៖ ខាងក្នុងដឹងអី គេមានស្លាប់ឬអត់ ។

ប៊ុនថន ៖ អញ្ចឹងអ្នកមីងនៅនេះ ខាងខ្មែរក្រហមបញ្ជូនឲ្យម៉ោនៅនេះវិញ ឬក៏មីងម៉ោនៅដោយខ្លួនឯង?

ភន ៖ ខ្មែរក្រហម ។

ប៊ុនថន ៖ កាលហ្នឹងយើងចុះចូលជាមួយរដ្ឋាភិបាលដែរ?

ភន ៖ ចា៎! រដ្ឋាភិបាលយើងដឹកនាំឲ្យម៉ោនេះវិញម៉ោ បញ្ជូនម៉ោនេះវិញម៉ោ ។

ប៊ុនថន ៖ ខាងណាអ្នកដឹងនាំមីង?

ភន ៖ ខាងកាលហ្នឹងខាងដូចកាកបាទទេអី ដូចខាងកាកបាទបារាំងទេអី គេជំនួយឲ្យយើងដូចជាអង្ករដូចជាអី យើងទៅនៅ យើងនៅជុំវិញហ្នឹងគេជំនួយសព្វ គេជំនួយតាំងពីត្រីខ ខ្ទះញ៉ាំសាប៊ូ អង្ករសព្វមុខទាំងអស់ អត់តែបិចេងមួយមុខទេ គេជំនួយឲ្យយើងសព្វ ។ ដល់ពេលយើងឡើងម៉ោនេះវិញ គេជូនឲ្យយើងឡើងម៉ោនេះវិញ ។

ប៊ុនថន ៖ ខាងអង្គរការហ្នឹងគេបញ្ជូនម៉ោ?

ភន : ចា៎ៗ! បញ្ជូនឲ្យឡើងម៉ោវិញ គេជំនួយតាំងពីលុយឲ្យយើង ជួយឲ្យយើងម៉ោដល់នេះ វិញ គេបើកលុយឲ្យយើងអញ្ចឹងណាស់ បើកលុយដូចជាយើងដឹកជញ្ជូនសំភារៈយើង ម៉ោមិនមានឡានមានអីដឹក ដល់អញ្ចឹងគេបើកលុយឲ្យយើងយករបស់របរអស់ហឹងម៉ោ ដល់នេះវិញ ថាអស់ប៉ុន្មានគេឲ្យប៉ុណ្ណឹង ។

ប៉ុនថន : បាទ! ហើយមីងម៉ោនេះមីងធ្វើអីទៅអ្នកមីងពីដំបូង?

ភន : ម៉ោដំបូងធ្វើចំការ យើងធ្វើចំការរាវធ្វើបានបន្តិចៗហ្នឹងខ្វាចមីន ។

ប៉ុនថន : មានមីនដែលមីង?

ភន : មាន ផ្លូវនេះអីសុទ្ធតែមីង រាវ៣-៤សារបានធ្វើផ្លូវហ្នឹង ។

ប៉ុនថន : ច្រើនទេអ្នកមីង?

ភន : ច្រើន! មីនច្រើន ឥឡូវក៏នៅក្រោយមួយៗដែរ ។

ប៉ុនថន : អ្ហូ! សព្វថ្ងៃនេះនៅមានមីនដែរ?

ភន : នៅក្រោយមួយៗទៀត នៅឃើញមីនឃើញអីទៀត ។

ប៉ុនថន : តែមានដែលគ្រោះថ្នាក់?

ភន : អត់អីទេ! អត់ដែលគ្រោះថ្នាក់ទេ អាឆ្នាំមុននោះឃើញស៊ីម៉ាក់រាវហើយ ឃើញមាន គ្រោះថ្នាក់ក្របីមួយទៀត ក្របីជាន់ទៅវាផ្ទុះ ។

ប៉ុនថន : ប៉ុន្តែមនុស្សអីអត់មានអីទេ?

ភន : អត់អីផង អត់មានគ្រោះថ្នាក់ទេ ។

ប៉ុនថន : អញ្ចឹងអ្នកមីងម៉ោដល់នេះ គេបញ្ជូនម៉ោដល់នេះអត់មានរបបចែកអីទេ?

ភន : អត់ៗ! អត់មាននទេ ពីហ្នឹងម៉ោយើងធ្វើផលិតផលខ្លួនយើងទៅ ។

ប៉ុនថន : បាទ!ហើយឆ្នាំ២០០០ហ្នឹង អ្នកមីងរៀបការមួយផងទៀតហ្នឹង គ្រួសារអ្នកមីងធ្វើកង ទ័ពដែរអ្នកមីង?

ភន : កងទ័ព ។

ប៉ុនថន : គ្រួសារក្រោយហ្នឹងគាត់កងទ័ពខាងក្នុងឬខាងខ្មែរក្រហម?

ភន : ខាងខ្មែរក្រហមយើងហ្នឹង ។

ប៉ុនថន : កាលហ្នឹងគាត់នៅកងជាមួយមីងដែរ?

ភន : ចា៎! នៅខ្មែរក្រហមដែរហ្នឹង ។

ប៉ុនថន : កងជាមួយគ្នាឬកងផ្សេងគ្នា?

ភន ៖ នៅកន្លែងផ្សេងគ្នា អត់គ្នាផង ។

ប៊ុនថន ៖ គាត់នៅខាងណាវិញអញ្ចឹង?

ភន ៖ គាត់នៅខាងអូរម្រិល ។

ប៊ុនថន ៖ អូរអំបិលមឹង?

ភន ៖ អូរម្រិល ។

ប៊ុនថន ៖ អូរម្រិល នៅសំឡូតដែរមឹង?

ភន ៖ អត់ទេ! នៅខាងអូរម្រិលយើងនេះ នៅម្តុំក្បាលឡាននេះ ។

ប៊ុនថន ៖ ម្តុំណាមឹង?

ភន ៖ ម្តុំក្បាលឡាន ។

ប៊ុនថន ៖ ខេត្តណាមឹង?

ភន ៖ នៅសំឡូតដែលហ្នឹង នៅខេត្តសំឡូតដែលហ្នឹង ។

ប៊ុនថន ៖ ស្រុកសំឡូត?

ភន ៖ ចា៎! នៅក្នុងស្រុកសំឡូតដែលហ្នឹង ប៉ុនគេហៅស្រុកផ្សេងៗគ្នាអញ្ចឹងណាស់ ដូចអូរសំឡូគេដាក់ឈ្មោះ ។

ប៊ុនថន ៖ បាទ! ហើយម៉េចបានឃើញគ្នាវិញ ទៅក្រោយនេះ?

ភន ៖ ទៅជិរុំទៅជួបគ្នា ដល់ជួបគ្នាទៅគេក៏ឃើញគ្នាទៅក៏គេទៅៗ ។

ប៊ុនថន ៖ អញ្ចឹងអ្នកមីងដែលទៅលេងស្រុកទេអ្នកមីង?

ភន ៖ ទៅ ។

ប៊ុនថន ៖ ខស្សរ៉ាហ៍ទៅទេអកមីង?

ភន ៖ ទៅញឹកដែរហ្នឹង ។

ប៊ុនថន ៖ ទៅបានប៉ុន្មានដងហើយមីង?

ភន ៖ ទៅបានច្រើនដងដែរតិចៗទៅៗ ។

ប៊ុនថន ៖ ចុះបងប្អូនអ្នកមីងនៅ?

ភន ៖ នៅឯស្រុកនោះ៤នាក់ ។

ប៊ុនថន ៖ ហើយនៅណាទៀតមីង ៤នាក់ហឹង?

ភន ៖ អត់មាននៅណាផងនៅជិតគ្នាហ្នឹង បងប្អូនវា៤នាក់នៅជិតគ្នាហ្នឹង ។

ប៊ុនថន ៖ បាទ!នៅជុំគ្នានៅស្រុក?

ភន : ចា៎! ជុំគ្នាហ្នឹង អត់មាននៅស្រុកផ្សេងៗទៀត បាត់អា២នាក់នោះបានឈឹងហ្នឹង មិនដឹងនៅណា ក៏មិនដឹងជាស្លាប់ ខ្ញុំថាស្លាប់ ប្រសិនជានៅរកម៉ែរកឪហើយ ។

ប៊ុនថន : បើនៅរត់ឡប់ម៉ោរកផ្ទះវិញ?

ភន : ចា៎! កាលហ្នឹងរកសួរគេ គេនៅជាមួយតាម៉ុក ។

ប៊ុនថន : នៅជាមួយតាម៉ុក?

ភន : ចា៎! គេថាបើកឡានឲ្យតាម៉ុក ។

ប៊ុនថន : អាហ្នឹងពួតាមពីណាវិញអ្នកមីង?

ភន : ពួតាមគេប្រាប់ ហើយគេប្រាប់ហ្នឹងមិនដឹងជាពិតឬមិនពិតទេ គេប្រាប់ដូចវាល្បៀកៗ ដែរ ។

ប៊ុនថន : ចុះមីងកាលហ្នឹងស្គាល់តាម៉ុកទេ?

ភន : ស្គាល់ ។

ប៊ុនថន : មីងស្គាល់គាត់ដែរ?

ភន : ស្គាល់ ។

ប៊ុនថន : គាត់នៅខាងណាវិញ?

ភន : ស្គាល់គាត់ តែមិនដឹងគាត់នៅខាងណា ។

ប៊ុនថន : ប៉ុនដែលជួបទេមីងពាឆ្នាំហ្នឹង?

ភន : ជួប ជំនាន់ពាឆ្នាំខ្ញុំឡើងម៉ោៗពីខេត្តស្រុកខ្ញុំនោះ ហើយឡើងម៉ោបាត់ដំបងហ្នឹង ម៉ោដល់តាម៉ុក អ្នករៀបចំឲ្យ ។

ប៊ុនថន : រៀបអីវិញមីង?

ភន : គាត់រៀបចំកងយើង ឲ្យយើងនៅតាមកងយើងទៅតាមកងណា៎ ដូចថាកងខ្ញុំកុមារតូចៗ អញ្ចឹងឲ្យទៅនៅរោងចក្រទៅ ដល់អាគេធំៗនារីៗហ្នឹងឲ្យទៅនៅតាមកងដូចជាចំការ កាហ្វេ ដូចជាធ្វើស្រែអញ្ចឹងទៅណា៎! ហ្នឹងហើយគាត់អ្នករៀបចំឲ្យយើងទៅ ។

ប៊ុនថន : កាលហ្នឹងម៉េចបានមីងស្គាល់គាត់ ដឹងថាតាម៉ុក?

ភន : ពួគេហៅថា ហ្នឹងហើយតាម៉ុក ។

ប៊ុនថន : រូបរាងគាត់យ៉ាងម៉េចវិញមីង?

ភន : រូបរាងគាត់ខ្មៅៗ ដែលរាងចំណាស់ហើយ ប៉ុនគាត់រាងនេះដែរតាម៉ុក បើថាគាត់មេធំ មែនពិតតែធ្វើដូចមនុស្សសាមញ្ញ ធ្វើដូចមនុស្សអត់មានភារៈកិច្ច ខ្ញុំឃាត់គាត់ម្ដងគេឃាត់គាត់ម្ដងបើកឡានចេញ អត់មានស្អីៗទេគេឃាត់ ឃាត់ឈប់ ឈប់នៅហ្នឹងដល់

តែនិរសាគាត់ម៉ោរកប៉ុនដឹងថា ហ្នឹងហើយតាម៉ុក គាត់អត់មានថាអីឲ្យគេទេ គាត់ចង់សាកយើងតើយើងហ្នឹងដឹងគាត់ឬអត់ គាត់ចង់សាកអញ្ចឹង ។

ប៉ុនថន : គាត់ម៉េចវិញ?

ភន : គាត់អត់អីទេ ។ ម៉េចគេហៅតាម៉ុក បើថាខុទាហរណ៍ថាបើឲ្យស៊ីណាហើយរូតយក អ្នកណាក៏គាត់ឲ្យដែរ ថាដើរជួបគាត់អញ្ចឹង គាសុំនាឡិកាមួយ គាត់ដោះឲ្យភ្លាត ។ ហ៊ី! យកពាក់ចុះ តិចបើថាមិនចេញអាមួយម៉ោពីក្រោយសុំទៀត ហែងពាក់ប៉ុនហ្នឹងបាន ហើយដោះឲ្យគេវិញម្ដង អាហ្នឹងហើយបានគេហៅតាម៉ុក ។

ប៉ុនថន : បាទ!អញ្ចឹងមិញមីងនិយាយថាឃាត់គាត់ជាប់ហ្នឹង គាត់ជិះឡានម៉េច?

ភន : គាត់ជិះឡាន កូនឡានតូចគាត់ជិះដើរលេងអញ្ចឹង ។

ប៉ុនថន : បាទ! ហើយខាងណាឃាត់មីង?

ភន : ខាង ដូចថាកាលហ្នឹងវាស្រុះស្រួលនឹងគ្នាហើយ មានយើងរាវមានវ៉ៃ នៅក្នុងស្រុក នោះទេមានវ៉ៃមានអីអញ្ចឹងទៅ យើងយាមកន្លែងវ៉ៃហ្នឹង កុំឲ្យអ្នកណាចូលម៉ោក៏គេមានគេយាមកាមអញ្ចឹងទៅ ដល់គាត់ចង់សាកមើលអ្នកយាមហ្នឹងរឹងពឹងឬអត់ គាត់ចង់សាកមើលទៅវឹងអញ្ចឹងទៅ គេឃាតពឹបអញ្ចឹងទៅ គាត់ឈប់ អ៊ូ!គាត់ដកពិសោធន៍ច្រើនណាស់ ។

ប៉ុនថន : គាត់ឈប់គាត់អត់មាននិយាយអីទេ?

ភន : អត់មានទេ ឈប់ឲ្យអង្គុយត្រង់ណាអង្គុយត្រង់ហ្នឹង អត់បាយមាំព្រឹកថ្ងៃត្រង់ ដល់កូននិរសាគាត់ម៉ោបានដឹងថាអ៊ូ! ហើយអាអ្នកយាមចុយម៉ាយហើយឃាត់អ្នកណាឃាតតាម៉ុក ។

ប៉ុនថន : បាទ! មីងនៅឃើញផ្ទាល់ភ្នែក?

ភន : ខ្ញុំនៅឃើញផ្ទាល់ភ្នែក ខ្ញុំឃើញយូរហើយឥឡូវភ្លេចមុខគាត់ហើយ ខ្ញុំនៅជិតៗគាត់ដែលហ្នឹងកាលហ្នឹង ។

ប៉ុនថន : ខស្សាហ៍បានជួបគាត់ទេអ្នកមីង?

ភន : ខស្សាហ៍បានជួបគាត់ដែលកាលហ្នឹង ។

ប៉ុនថន : ចុះគាត់និយាយលេងអីធម្មតាទេ?

ភន : គាត់និយាយលេងធម្មតា អត់មានរំកែងឬកថាគាត់នឹងមេធំមេអីអត់ទេ ។

ប៉ុនថន : គាត់ដូចចិត្តល្អជាមួយកូនចៅ?

ភន ៖ គាត់ចិត្តល្អណាស់តាម៉ុក ។

ប៊ុនថន ៖ ចុះអ្នកនៅកងអីចូលចិត្តគាត់ទេអ្នកមីង?

ភន ៖ ចូលចិត្តដែរ នៅតាមកងអីគេចូលចិត្តតាម៉ុក ចូលចិត្តតែគាត់វាស្រួល តែឥឡូវពូថា គាត់គុកជាប់អីមិនដឹងខ្ញុំមិនដឹងដែរ ។

ប៊ុនថន ៖ គាត់ស្លាប់ហើយមីង ។

ភន ៖ ស្លាប់ហើយ?

ប៊ុនថន ៖ បាទ! ស្លាប់ហើយ ។

ភន ៖ អ្ហូ!

ប៊ុនថន ៖ អញ្ចឹងមីងក្រៅពីតាម៉ុកអី មីងដែលបានជួបអ្នកណាទៀតដូចថាធំៗអីនៅនោះទៀតទេ អ្នកមីង?

ភន ៖ អត់ ។

ប៊ុនថន ៖ អត់ដែលជួបទេ?

ភន ៖ អត់ ។

ប៊ុនថន ៖ សួរអ្នកមីងបន្តទៀត អ្នកមីងបែកពីផ្ទះតាំងពីតូចម៉ោមីងដែលទៅសួរដំណឹងពីគាត់ទេ តាំងពីមីងចូលកងដែលបានទាក់ទង?

ភន ៖ សួរដំណឹងពីអ្នកណាគេ?

ប៊ុនថន ៖ ពីឪពុកម្ដាយ បងប្អូនអ្នកមីង?

ភន ៖ អត់សោះៗ ទាស់តែខ្ញុំបានប្ដី៩៦ហ្នឹង ។ គាត់ថាខ្ញុំស្លាប់ហើយ គាត់ថាស្លាប់អញ្ចឹងទៅ គាត់អត់សួររក ដល់ក្រោយម៉ោគាត់បានដំណឹងដែលកងទ័ពទៅហ្នឹង គាត់បានដំណឹង ដល់អញ្ចឹងគាត់អត់ជឿៗទេ គាត់ថាប្រសិនបើជាកូនគាត់នៅរស់មែនឲ្យយករូបថតឲ្យ គាត់មើល អញ្ចឹងក៏កងទ័ពហ្នឹងគេម៉ោទាក់ទងខ្ញុំថា សុំរូបថតមួយសន្លឹក យកទៅឲ្យម៉ែខ្ញុំ ពុកខ្ញុំ ដល់យកឲ្យទៅគាត់ឃើញកូននៅរស់ពិតប្រាកដមែន គាត់ម៉ោរកខ្ញុំដល់អីសំឡូត នោះ គាត់ម៉ោអ្ហូជាច់ដើងអស់ហើយទឹកស៊ី ។

ប៊ុនថន ៖ កាលហ្នឹងគាត់ជួបមីងទេ?

ភន ៖ ជួប ។

ប៊ុនថន ៖ ជួបនៅសំឡូត?

ភន ៖ ចា៎! ជួបនៅសំឡូត ។

ប៊ុនថន ៖ ចុះជួបអញ្ចឹងស្គាល់ទេអ្នកមីង?

ភន ៖ ស្គាល់ៗម៉ែខ្ញុំក៏ស្គាល់ ខ្ញុំក៏ស្គាល់គាត់ គាត់ក៏ស្គាល់ខ្ញុំ គាត់ថាអត់ប្លែកផង ។

ប៊ុនថន ៖ និយាយពីមីងម៉ោនៅស្រុកហ្នឹងដំបូង ប្លែកយ៉ាងម៉េចដែរអ្នកមីង តាំងពីមីងម៉ោនៅដំបូងរហូតមកដល់សព្វថ្ងៃនេះ ?

ភន ៖ ប្លែកច្រើន ។

ប៊ុនថន ៖ ប្លែកយ៉ាងម៉េចខ្លះ?

ភន ៖ ប្លែកមានផ្លូវដើរមានឡាន មានម៉ូតូ មានជីវភាព មានកន្លែងធ្វើចំការប្លែកច្រើនណាស់ ។

ប៊ុនថន ៖ បាទ!ហើយសព្វថ្ងៃមានកូនប៉ុន្មាននាក់អ្នកមីង?

ភន ៖ ៥នាក់ ។

ប៊ុនថន ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មានអ្នកមីង?

ភន ៖ ប្រុស៣នាក់ ស្រី២នាក់ ។

ប៊ុនថន ៖ បាទ! មានបានរៀនសូត្រអីទេអ្នកមីង?

ភន ៖ មាន ។

ប៊ុនថន ៖ រៀនទាំងអស់គ្នាអ្នកមីង?

ភន ៖ ចា៎! ហ្នឹងទើមម៉ោពីរៀនមិញហ្នឹង ។

ប៊ុនថន ៖ ចុះមីងដែលឮតុលាការកាត់ទោសខ្មែរក្រហមទេអ្នកមីង?

ភន ៖ ដែលឮគេកាត់ទោសដែលហ្នឹង ខ្ញុំស្តាប់ក្នុងរ៉ាត់យូ ប៉ុន្តែស្តាប់មិនសូវបាន ។

ប៊ុនថន ៖ អញ្ចឹងមីងយល់យ៉ាងម៉េចដែរ ដូចថាមីងធ្លាប់បម្រើឲ្យខ្មែរក្រហមឥឡូវគេកាត់ទោសមេដឹកនាំខ្មែរក្រហមអ្នកមីង?

ភន ៖ ខ្ញុំអត់យល់ថាម៉េចផង ។

ប៊ុនថន ៖ បាទ! ដូចថាមីងគិតឃើញថា ជាការត្រឹមត្រូវឬមួយអត់ត្រឹមត្រូវដោយសារខ្មែរក្រហមធ្លាប់តស៊ូអីដែរមីង?

ភន ៖ អត់ដែលបានស្តាប់គេនិយាយឲ្យច្បាស់លាស់ផង បានបើករ៉ាត់យូទៅជួនអីទៅចុងក្រោយហើយ ស្តាប់ឮគេថាកាត់ទោសខ្មែរក្រហមតែមួយម៉ាត់ហ្នឹងចប់បាត់ទៅ អត់បានស្តាប់ពីដើមដល់ចប់ មិនដឹងគេថាម៉េចខ្លះ ។

ប៊ុនថន ៖ ហើយអ្នកមីងមានអីចង់បន្ថែមទៀតទេមីង?

ភន ៖ អត់ផង អត់មានអី ។

ប៊ុនថន ៖ អញ្ជើងខ្ញុំអរគុណអ្នកមីងច្រើនអ្នកមីង?

ភន ៖ ចាំ!

**ចប់**